ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១៥២ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្ម នៃក្រសួងទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៥ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់របនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្ត ទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្ម នៃក្រសួងទេសចរណ៍។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ធានាគុណភាព ប្រសិទ្ធិភាពការងារ និងភាពទទួលខុសត្រូវរបស់នាយកដ្ឋាននីតិកម្ម
- ជំរុញការរៀបចំ ផ្សព្វផ្សាយ និងអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាលើវិស័យទេសចរណ៍ ឈរលើគោលការណ៍នីតិរដ្ឋ។

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋាននីតិកម្ម** ជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារសិក្សាស្រាវជ្រាវ រៀបចំផ្សព្វផ្សាយ តាមដានការអនុវត្ត និងវាយតម្លៃផលប៉ះពាល់នៃបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យទេសចរណ៍ និងបទប្បញ្ញត្តិផ្សេងៗ លើការងារទេសចរណ៍។

**នាយកដ្ឋាននីតិកម្ម** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យទេសចរណ៍ និងបទប្បញ្ញត្តិផ្សេងៗលើការងារទេសចរណ៍ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវលើច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍
- ធ្វើបច្ចុប្បន្នកម្ម និងសិក្សាវាយតម្លៃផលប៉ះពាល់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- សហការធ្វើវិសោធនកម្មច្បាប់ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធលើការគ្រប់គ្រងវិស័យទេសចរណ៍
- ចងក្រងបោះពុម្ព និងតម្កល់ឯកសារបទដ្ឋានគតិយុត្តនានា
- ផ្សព្វផ្សាយ និងតាមដានការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យទេសចរណ៍
- រៀបចំវគ្គបណ្តុះបណ្តាល អប់រំទាក់ទងទៅនឹងការងារនីតិកម្មក្នុងវិស័យទេសចរណ៍
- សម្របសម្រួល ផ្សះផ្សា និងដោះស្រាយវិវាទទេសចរណ៍ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងទេសចរណ៍ និងក្រសួងស្ថាប័នពាក់ព័ន្ធ
- ត្រួតពិនិត្យ តាមដានលើសកម្មភាពអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

នាយកដ្ឋាននីតិកម្ម ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋាននីតិកម្មមានការិយាល័យចំណុះចំនួន **០៤ (បួន)** ដូចខាងក្រោម៖

១-ការិយាល័យនីតិកម្ម

២-ការិយាល័យពង្រឹងការអនុវត្តច្បាប់

៣-ការិយាល័យស្រាវជ្រាវ និងវាយតម្លៃពីផលប៉ះពាល់គតិយុត្តទេសចរណ៍

៤-ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋាននីតិកម្ម ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យនីតិកម្ម** មានតួនាទី និងភារកិច្ច៖

- រៀបចំផែនការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទេសចរណ៍នានា
- រៀបចំបង្កើត និងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងឧស្សាហកម្មទេសចរណ៍ ឱ្យឆ្លើយតបទៅនឹងការវិវឌ្ឍនៃសង្គម និងសេដ្ឋកិច្ច
- សហការ និងសម្របសម្រួលជាមួយនឹងនាយកដ្ឋានជំនាញ និងក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំបង្កើត និងធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- រៀបចំ និងជំរុញការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ដោយសហការជាមួយក្រសួងស្ថាប័ន នាយកដ្ឋានពាក់ព័ន្ធ សមាគមឧស្សាហកម្មទេសចរណ៍ និងអ្នកពាក់ព័ន្ធ
- តាមដាន និងចូលរួមកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធនឹងក្រមសីលធម៌វិជ្ជាជីវៈសាកលរបស់អង្គការទេសចរណ៍ពិភពលោក
- ត្រួតពិនិត្យ និងផ្តល់យោបល់លើទម្រង់ និងវិធាននៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទេសចរណ៍ ដែលរៀបចំដោយនាយកដ្ឋានជំនាញ និងក្រសួងស្ថាប័នពាក់ព័ន្ធ
- ពិនិត្យ និងផ្តល់យោបល់អំពីទម្រង់ និងខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យា អនុស្សរណៈនៃការយោគយល់គម្រោងវិនិយោគដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- ចូលរួមសហការ ពិនិត្យ និងផ្តល់យោបល់ ដើម្បីចាត់វិធានការដាក់ពិន័យលើបុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានា។

**២-ការិយាល័យពង្រឹងការអនុវត្តច្បាប់** មានតួនាទី និងភារកិច្ច៖

- ត្រួតពិនិត្យ តាមដាន ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យទេសចរណ៍
- ពង្រឹង និងជំរុញការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យទេសចរណ៍
- សហការចូលរួមពិនិត្យ និងផ្តល់យោបល់ ដើម្បីចាត់វិធានការផាកពិន័យអន្តរការណ៍លើបុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានា
- ជំរុញការអនុវត្តក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈទេសចរណ៍ចំពោះប្រតិបត្តិករទេសចរណ៍ ទេសចរ និងភាគីពាក់ព័ន្ធ
- ត្រួតពិនិត្យ តាមដាន និងទទួលស្គាល់ក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ដែលបង្កើតដោយសមាគមឧស្សាហកម្មទេសចរណ៍
- សហការពិនិត្យ និងសម្របសម្រួល ដោះស្រាយ និងផ្សះផ្សាវិវាទទេសចរណ៍

- សហការចូលរួម និងផ្តល់ការប្រឹក្សាផ្លូវច្បាប់ដល់គ្រប់អង្គភាពក្រោមឱវាទក្រសួងលើការងារនីតិកម្ម និងវិវាទទាំងឡាយណាដែលពាក់ព័ន្ធក្រសួងទេសចរណ៍ និងមន្ត្រីរាជការ។

**៣-ការិយាល័យស្រាវជ្រាវ និងវាយតម្លៃពីផលប៉ះពាល់គតិយុត្តទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- សិក្សាស្រាវជ្រាវ ផលប៉ះពាល់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- វាយតម្លៃផលប៉ះពាល់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- ចូលរួមសហការ និងសម្របសម្រួលជាមួយនឹងក្រសួងស្ថាប័ន នាយកដ្ឋានពាក់ព័ន្ធក្នុងការងារសិក្សាស្រាវជ្រាវ និងវាយតម្លៃផលប៉ះពាល់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- សហការ និងសម្របសម្រួលជាមួយក្រសួងស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធក្នុងការងាររៀបចំបង្កើត ធ្វើបច្ចុប្បន្នកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលប៉ះពាល់ទៅលើ ឬទទួលរងប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍
- រៀបចំផែនការសម្រាប់វាយតំលៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តទេសចរណ៍
- បណ្តុះបណ្តាល និងកសាងសមត្ថភាពជូនមន្ត្រីអំពី វិធីសាស្ត្រការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត
- ផ្តល់យោបល់ជូនក្រសួង ក្នុងការរៀបចំរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ធ្វើបច្ចុប្បន្នកម្ម រៀបចំបោះពុម្ព និងផ្សព្វផ្សាយអំពី គោលការណែនាំស្តីពី វិធីសាស្ត្រការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

**៤-ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ** មានតួនាទី និងភារកិច្ចៈ

- ផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យទេសចរណ៍
- ចងក្រងបោះពុម្ព និងតម្កល់ច្បាប់ និងឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- សម្របសម្រួល សហការរៀបចំសិក្ខាសាលានានា ដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យទេសចរណ៍
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយជូនមន្ត្រីក្រសួងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋទាក់ទងទៅនឹងនីតិកម្មក្នុងវិស័យទេសចរណ៍
- រៀបចំការបណ្តុះបណ្តាលជូនមន្ត្រីនាយកដ្ឋាននីតិកម្មដើម្បីពង្រឹងសមត្ថភាព និងគុណភាពការងារ
- សិក្សាស្រាវជ្រាវលើច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធលើការគ្រប់គ្រង និងអភិវឌ្ឍនវិស័យទេសចរណ៍។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យនាយកដ្ឋាននីតិកម្មមានតួនាទី និងភារកិច្ចៈ

- ធ្វើកំណត់ហេតុប្រជុំដែលពាក់ព័ន្ធនឹងការងារទទួលខុសត្រូវរបស់ការិយាល័យសាមី
- រៀបចំគម្រោងផែនការសកម្មភាពការងារ និងថវិកាចំណាយផ្សេងៗ និងប្រចាំឆ្នាំរបស់ការិយាល័យជូនប្រធាននាយកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋាននីតិកម្ម ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ